# ការចិញ្ចឹមមាន់ជាលក្ខណៈគ្រួសារ

◆ **សារៈប្រយោជន៍ និង លក្ខណៈសម្បត្តិនៃការចិញ្ចឹមមាន់**

-ងាយបន្សាំទៅនឹងអាកាសធាតុស្រុកស្រែ

-មានការលូតលាស់ឆាប់រហ័ស ។

-សាច់ និងស៊ុតប្រើប្រាស់ជាចំណីអាហារ

-ទុកពូជបានសំរាប់ចិញ្ចឹមបន្ត

-ផ្តល់លាមកជាជី និងជាចំណីសត្វ

-បង្កើនប្រាក់ចំណូលគ្រួសាររបស់ប្រជាកសិករ

◆ តំរូវការសំខាន់ៗក្នុងការចិញ្ចឹមមាន់

-ការចេះធ្វើផែនការចិញ្ចឹម

-ពូជ

-ទីកន្លែងនិង ទ្រុង

-ចំណីនិង ទឹក

-អនាម័យ និងការថែទាំ

-ការព្យាបាល និងការការពារ

-ការយល់ដឹងពីជំងឺផ្តាសាយបក្សី

-ការប្រមូលលក់និង ការទុកពូជ



◆ **ការជ្រើសរើសមាន់មកចិញ្ចឹមយកសាច់**

គឺត្រូវជ្រើសយកពូជមាន់កូនកាត់ រវាងមាន់ពូជយកសាច់ ឬមាន់ពូជយកពង បង្កាត់ នឹង ពូជមាន់ក្នុងស្រុក ជាពូជមាន់កណ្តូងខ្លួនធំ ព្រោះការលូតលាស់របស់វាលឿនដែលនាំអោយរយៈពេលនៃការចិញ្ចឹមប្រមាណជាង ៣ ខែអាចលក់បាន ។




◆ **ការចិញ្ចឹមមេមាន់ដើម្បីយកពងភ្ញាស់/កូន**

មាន់មេចាប់ផ្តើមពងនៅអាយុ ៥ ខែឡើងទៅ។ ការចិញ្ចឹមមេមាន់ត្រូវថែរក្សាដោយយកចិត្តទុកដាក់ គឺផ្តល់ចំណីអាហារអោយបានគ្រប់គ្រាន់ និងមានគុណភាពល្អ ដូចជា ÷ ម្សៅត្រី កន្ទក់ ចុងអង្ករ ទឹកស្អាត.........។



◆ **ការជ្រើសរើសទីកន្លែង**

ដីទួលមិនលិចទឹក ជិតប្រភពទឹក អាកាសធាតុល្អ ឆ្ងាយពីព្រៃ មានដើមឈើបន្តិចបន្តួច ក្បែរផ្ទះ មានស្មៅដុះ ទីធ្លា ទូលាយ ហ៊ុំព័ទ្ធសំណាញ់ជុំវិញកំពស់ ៣.៥ម៉ែត្រ ។



**.ការថែទាំមាន់**

ជាទូទៅគេអាចចិញ្ចឹមមាន់បានគ្រប់រដូវ ។ ប៉ុន្តែរដូវដែលសមស្របបំផុតសំរាប់ចិញ្ចឹមមាន់អោយបានធំធាត់រហ័ស គឺនៅរដូវភ្លៀង និងដើមរដូវរំហើយ ។

**របៀបថែទាំកូនមាន់ក្រោយពេលញាស់**

-មុនដាក់កូនមាន់ចេញពីសំបុកត្រូវក្រាលកំទេចចំបើង ឬអាចម៍រណាជាមុនសិន ។

-ត្រូវឧស្សាហ៍ផ្លាស់ប្តូរកំទេចចំបើង ឬ អាចម៍រណានៅពេលវាសើម ឬមានក្លិនមិនល្អ ។

-កូនមាន់ទើបញាស់មានអាយុ១២ម៉ោងដំបូងកុំអាលឱ្យចំណីស៊ី ព្រោះវានៅមានសារធាតុចិញ្ចឹមបំរុងខ្លួនវានៅឡើយ ។

-កូនមាន់អាយុ ២-៣ថ្ងៃ ត្រូវកាត់ចំពុះលើកទី១ (កាត់ចុងចំពុះខាងលើអោយខ្លីជាងខាងក្រោម)ដើម្បីងាយអោយសត្វចឹកចំណី ។

-កូនមាន់អាយុ ២សប្តាហ៍ត្រូវកាត់ចំពុះលើកទី ២ទៀត ការពារកូនមាន់ចឹកគ្នា ឬចឹកកាយចំណីចោល ។

-ត្រូវលាងស្នូកទឹក ឬ ស្នូកចំណីអោយបាន ២ដងក្នុង១ថ្ងៃ ។ ត្រូវប្រើទឹកក្រេស៊ីល ឬ ហ្វ័រម៉ុល បាញ់លើផ្ទៃក្នុងទ្រុងអោយបាន ២ ដង ក្នុង ១ ឆ្នាំ ដើម្បីរំងាប់មេរោគ ។

◆កំណត់សំគាល់

-គេអាចប្រើចង្កៀងប្រេងកាត ឬ អំពូលអគ្គីសនី សំរាប់កំដៅកូនមាន់នៅកន្លែងចិញ្ចឹម ព្រោះវាត្រូវការកំដៅណាស់ក្នុងដំណាក់កាលនោះ ។

-បើកូនមាន់ទទួលកំដៅមិនបានគ្រប់គ្រាន់ធ្វើអោយកូនមាន់ដេកផ្តុំគ្នា ។

-បើកូនមាន់ទទួលកំដៅខ្លាំងពេកធ្វើអោយកូនមាន់ដេកបែកពីគ្នា ។

-បើកូនមាន់ទទួលកំដៅល្មមនោះកូនមាន់ដេក ឬ ដើររើសចំណីក្នុងទ្រុងស៊ី ។

## តំរូវការទឹកសំរាប់កូនមាន់

| ចំនួនកូនមាន់ (ក្បាល ) | អាយុកូនមាន់ (សប្តាហ៍ ) | ចំនួនទឹក ក្នុង១ថ្ងៃ |
|---|---|---|
| ១00 | ១ | ៤ លីត្រ |
| ១00 | ២ | ៥ លីត្រ |
| ១00 | ៣ | ៦ លីត្រ |
| ១00 | ៤ | ១0 លីត្រ |



**◆របៀបផ្តល់ទឹក និងចំណី**

-ចំណីមាន់ត្រូវផ្តល់ ៣ដង ក្នុងមួយថ្ងៃ (ករណីចិញ្ចឹមលែងផ្តល់ឱ្យតែ២ដងក្នុងមួយថ្ងៃ គឺពេលព្រឹក និងពេលល្ងាច )ដោយមានស្នូកចំណីឱ្យបានត្រឹមត្រូវចៀសវាង ការខ្ជះខ្ជាយចំណីឥតប្រយោជន៍ ។

-ការផ្តល់ទឹក គឺទឹកស្អាត ដោយប្រើចានជ័រ ចានដែកធម្មតាឈើធ្វើជាស្នូកទឹក ដែក ស័ង្កសី ឬក៏អាចជាបំពង់ទីបស្វ័យ -ប្រវត្តិឱ្យមាន់ចឹក ។

**◆លក្ខណៈវ៉ាក់សាំង**

- វ៉ាក់សាំងគឺ ជាប្រភេទថ្នាំម្យ៉ាងដែលមានលក្ខណៈខុសពីប្រភេទថ្នាំព្យាបាល ។ គេផលិតថ្នាំវ៉ាក់សាំងពី បាក់តេរី ឬវីរុស (រស់) ព្រមទាំងគ្រឿងបន្សំផ្សេងទៀតទៅតាមប្រភេទវ៉ាក់ -សាំងនីមួយៗ ។

-វ៉ាក់សាំងគឺជាថ្នាំសំរាប់ការពារ ជំងឺឆ្លងរាតត្បាតវាមិនមែនជាថ្នាំព្យាបាលទេ ។

-ថ្នាំការពារប្រឆាំង និងជំងឺមួយ ធ្វើឡើងដោយមេរោគនៃជំងឺនោះដែលត្រូវបានគេធ្វើអោយខ្សោយ ។

-ចាក់ថ្នាំការពារវាមិនបណ្តាលអោយសត្វកើតជំងឺនោះទេ និងធ្វើអោយខ្លួនសត្វមានលទ្ធភាពទប់ទល់មេរោគនោះបាន ។

-វ៉ាក់សាំងមួយប្រភេទគឺ ការពារបានជំងឺតែមួយមុខគត់ ។

## វិធីសាស្រ្តផ្តល់ថ្នាំការពារ ដល់បក្សី(មាន់)

